# ជលជាតិ ៨ ប្រភេទ

## (រុក្ខជាតិដែលដុះក្នុងទឹក)



**ឧប្បល** : (នប៉ុ.) [ឧ+បា+អល] ជលជាតតែងអណ្ដែតលើទឹកឬ ជលជាតតែងផឹកនូវទឹក (ឧប្បល, ផ្កាឧប្បល ដូចព្រលិត); វិគ្គហៈ ឧទកេ ប្លវតីតិ > ឧប្បលំ, ឧទកំ បិវតីតិ វា > ឧប្បលំ ។

**នីលុប្បល** : ឧប្បលខៀវ, ព្រលិតខៀវ

**បទុម** : (នបុំ.) [បទិ+កុម ឬ ប+ទរិ+ឧម] ផ្កាដល់នូវការបូជាមានការបូជានៃទេវតាជាដើម ឬ ជលជាតដុះក្នុងភក់ (ឈូក, ផ្កាឈូកក្រហម); វិគ្គហៈ បជ្ជតិ ទេវបូជាទឹ យាតីតិ > បទុមំ, បម្ទិ បង្កម្ទិ ទវតិ វុហាតីតិ វា > បទុមំ ។

**កុមុទ** : (នបុំ.) [កុ + មុទ + ណ] (ជលជាត) ត្រេកអរក្នុងទឹក ឬត្រេកអរក្នុងផែនដី (កុមុទ, ផ្កាកុមុទ), វិគ្គហៈ កុយំ បថវិយំ មោទតីតិ >កុមុទំ ។

**វារិជ** : ឈូក, ផ្កាឈូក

**អរវិន្ទ** : ឈូក, ផ្កាឈូក

**កុលវយ** : ឈូក, ផ្កាឈូក

**បុណ្ឌរីក** : ឈូកស

(សទ្ទានុក្រមបាលី)

*ក្នុងជលជាតិទាំងអស់នេះ បទុម គឺបុព្វនិមិត្តនៃការកើតឡើងរបស់ព្រះសម្មាសម្ពុទ្ធក្នុងកប្បនីមួយៗ ។ ក្នុងពេលដែលកប្បត្រូវកសាងឡើងនោះ ស្ថានទីមហាពោធិបល្ល័ង្កដែលជាកន្លែងត្រាស់របស់ព្រះពុទ្ធនោះ មានឈូកមួយគុម្ព បានកើតឡើងជាបុព្វនិមិត្ត ប្រសិនបើក្នុងកប្បនោះ មានព្រះពុទ្ធនឹងឧប្បត្តិ ផ្កាឈូករមែងកើតឡើង (ជានិមិត្ត) បើព្រះពុទ្ធមិនឧប្បត្តិទេ ផ្កាឈូកនឹងមិនកើតដែរ ។ បើព្រះពុទ្ធនឹងឧប្បត្តិឡើង ១ អង្គ ផ្កាឈូកក៏កើតឡើង ១ ផ្កា ។ បើព្រះពុទ្ធ ២ អង្គ ៣ អង្គ ៤ អង្គ ៥ អង្គ ផ្កាឈូកក៏កើត (២, ៣, ៤) ៥ ផ្កា ។ មួយទៀត ផ្កាឈូកទាំងនោះ ជាផ្កាមានចង្កោមជាប់គ្នាក្នុងទងតែមួយប៉ុណ្ណោះ ។ សុទ្ធាវាព្រហ្មទាំងឡាយបបួលគ្នាថា ម្នាលអ្នកនិរទុក្ខទាំងឡាយ ពួកយើងចូរមក នឹងឃើញនូវបុព្វនិមិត្ត ហើយនាំគ្នាកាន់ស្ថានទីមហាពោធិបល្ល័ង្ក ។ បើក្នុងកប្បដែលព្រះពុទ្ធទាំងឡាយមិនឧប្បត្តិឡើង ផ្កាឈូកក៏មិនមានដែរ ។ ពួកព្រហ្មទាំងឡាយនោះឃើញគុម្ពឈូកមិនមានផ្កា ក៏មានសេចក្តីសង្វេគថា ម្នាលគ្នាយើង លោកនឹងងងឹតឈឹងហ្នុំ, សត្វទាំងឡាយត្រូវភាពងងឹតគ្របសង្កត់ហើយ នឹងពេញក្នុងអបាយ, ទេវលោក ៦ ព្រហ្មលោក ៩ នឹងទំនេរ ។ កាលបានឃើញផ្កាឈូកក្នុងវេលារីកឡើង នាំគ្នាសប្បាយចិត្តថា កាលព្រះសព្វញ្ញូពោធិសត្វទ្រង់ឈាន*

ចុះកាន់គភ៌ព្រះមាតា ទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ធ្វើយមកបាដិហារ្យ ទ្រង់យាងចុះចាកទេវលោក ទ្រង់ដាក់អាយុសង្ខារ ស្ដេចរំលត់ខន្ធបរិនិព្វាន ពួកយើងនឹងឃើញបាដិហារ្យ ដែលធ្វើឲ្យម៉ឺនចក្រវាឡញាប់ញ័រ ហើយក៏មានចិត្តគិតថា អបាយទាំង ៤ នឹងវិនាសសាបសូន្យ, ទេវលោក ៦ ព្រហ្មលោក ៩ នឹងបរិបូណ៌ ដូច្នេះហើយក៏នាំគ្នាថ្លែងឧទានទៅកាន់ព្រហ្មលោករបស់ខ្លួនរៀងៗខ្លួន ។

ម្យ៉ាងទៀត ផ្កាឈូកទាំងឡាយ ៥ កើតឡើងហើយក្នុងភទ្ទកប្បនេះ ។ ព្រះពុទ្ធទាំងឡាយ ៤ អង្គបានកើតឡើងដោយអានុភាពនៃនិមិត្តទាំងឡាយនោះ ហើយអង្គទី ៥ នឹងកើតឡើង ។ សុទ្ធាវាសព្រហ្មទាំងឡាយបានឃើញផ្កាឈូកទាំងនោះ ទើបដឹងនូវសេចក្ដីនោះ ។ ព្រោះហេតុនោះ លោកទើបពោលថា សេចក្ដីនោះជាការប្រាកដ សូម្បីដល់បុគ្គលដទៃដោយប្រការដូច្នេះ ។

( សុមង្គលវិលាសិនី អដ្ឋកថា ទីឃនិកាយ មហាវគ្គ មហាបទានសុត្តវណ្ណនា បុព្វេនិវាសបដិសំយុត្តកថា)

ដោយខេមរ អភិធម្មាវតារ